ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


០៤-៧-២០១១ -ព្រះរាជក្រម នស/រកម/០៧១១/០១២ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ៥២៥៤

០៤-៧-២០១១ -ព្រះរាជក្រម នស/រកម/០៧១១/០១៣ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៥២៥៦


### ២~ព្រះរាជក្រឹត្យ


១៥-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៦៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ សមាជិក សមាជិកា នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំនួន ០៦ រូប ៥២៦៦

១៧-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៧១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម និង ឯកឧត្តមឧកញ៉ា ចំនួន ០២ រូប ៥២៦៧

២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៨៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា និង សប្បុរសជន ចំនួន ២៣ រូប ៥២៦៨

២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៨៨ ស្តីពី ការតែងតាំងឯកឧត្តម ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ចំនួន ០២ រូប ៥២៦៩

២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩១ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូន នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៥២៧០

២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន ចន** (CHEN JOHN) ជនជាតិចិន សញ្ជាតិអាមេរិក កើតនៅ ខេត្តហ្វ៊ូគៀន សាធារណរដ្ឋប្រជាមានិតចិន ៥២៧១

២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គីម ចូ ដុគ** (KIM JOO DEOG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅខេត្តប៉ាំងជីសាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះ ជា **គីម តារា** (KIM TARA) ៥២៧២

២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ចំនួន ១១ រូប ៥២៧៣

២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩៥ ស្តីពី ការតម្លើងថ្នាក់តាមកម្រិតសញ្ញាប័ត្រ ជូនមន្ត្រីរាជការ ចំនួន ០៤ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ៥២៧៤
២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ប្រគេនព្រះតេជគុណ សៀម សុខណ្ណដា ៥២៧៥
២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម ខួន ស្រេង ៥២៧៦
២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩៨ ស្តីពី ការតែងតាំង ឯកឧត្តម សុខ ចំរើន ជាឧកញ៉ា ៥២៧៧
២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៩៩ ស្តីពី ការតែងតាំង លោក សុខ ខណ្ណា ជាឧកញ៉ា ៥២៧៨
២០-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៦០០ ស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ ៥២៧៩

## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

២៨-៦-២០១១ -អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសារខ្មែរ ៥២៨៣
៣០-៦-២០១១ -អនុក្រឹត្យលេខ ១៣៩ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៥២៨៩
០៦-៧-២០១១ -អនុក្រឹត្យលេខ ១៤០ អនក្រ.បក ស្តីពី ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ សម្រាប់អាណត្តិទី ១ ៥២៩១
០៦-៧-២០១១ -អនុក្រឹត្យលេខ ១៤១ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៤៨៨ ហិកតា ស្ថិតនៅ ក្នុងភូមិសាស្រ្ត ស្រុកជ័យសែន ខេត្តព្រះវិហារ ៥២៩៣
២១-៦-២០១១ -អនុក្រឹត្យលេខ ៧៣៩ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស ៥២៩៦
២១-៦-២០១១ -អនុក្រឹត្យលេខ ៧៤០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៣០៤
២១-៦-២០១១ -អនុក្រឹត្យលេខ ៧៤១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិមន្ត្រីរាជការ ៥៣០៥
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៤២ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥៣០៧
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៤៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៣០៨
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៤៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៣០៩
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៤៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៣១០

២២-៦-២០១១ -អនុក្រឹត្យលេខ ៧៤៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៣១១
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៤៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ៥៣១២
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៤៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៥៣១៣
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៤៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៣១៧
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៥០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៣១៨
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៥១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៣១៩
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៥២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៣២០
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៥៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៣២១
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៥៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៣២២
២២-៦-២០១១ -អនុក្រឹត្យលេខ ៧៥៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៣២៣

## ២-សេចក្តីសំរេច

២៧-៦-២០១១ -សេចក្តីសំរេចលេខ ៣៨ សសរ ស្តីពី ការបង្កើតគណៈកម្មការផ្តល់យោបល់ណែនាំសម្រាប់គម្រោង "ក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌតំបន់អង្គរ " ដែលសហការជាមួយប្រទេសអូស្ត្រាលី និង អង្គការយូណេស្កូ ៥៣២៤
០១-៧-២០១១ -សេចក្តីសំរេចលេខ ៣៩ សសរ ស្តីពី ការបង្កើតគណៈកម្មការអធិការកិច្ច លើការគ្រប់គ្រង និង អភិវឌ្ឍន៍ឡូតិ៍នេសាទ ជុំវិញបឹងទន្លេសាប ៥៣២៦

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៥-៥-២០១១ -ប្រកាសលេខ ៣៧១ សហវ.ប្រក ស្តីពី តម្លៃគិតពន្ធលើអចលនទ្រព្យ
*(ត មកពីរាជកិច្ច លេខ ៤៩-៥០)* ៥៣២៨

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៧៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ឆាយនិស អ៊ិនដាសស្ទ្រៀល ហ្សូន អ៊ិនវេសមេន មេនេចមេន** ៥៣៦០
១១-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៧៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខូដ លែន** ៥៣៦២
១១-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៧៥២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី អេ ស៊ី អេស អ៊ិនវេសមេន លីមីធីត** ៥៣៦៤

១២-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៧៥៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគន្តខ្រឹម អ៊ិនខបភើរេសិន** ៥៣៦៦

១២-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៧៥៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេនើរ៉ែល អេច យូ ឌី ខូ អិលធីឌី** ៥៣៦៨

១២-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៧៦៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌ៉ារិទ្ធិ ឌីវេឡុបមេន & អ៊ីមផត អិចផត** ៥៣៧០

១២-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៧៦៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាន ហ្វាម៉ា** ៥៣៧២

# ព្រះរាជក្រម

នស/រកម/០៧១១/០១២

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្ដីសម្រេចលេខ ១១៧/០០៥/២០១១ កបធ.ច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## វិសោធនកម្មច្បាប់ស្តីពី
## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រាមួយ._**

មាត្រា ១៩០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

**មាត្រា ១៩០._ ថ្មី(ពីរ)**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៣ ត្រូវធ្វើនៅថ្ងៃអាទិត្យ ទី ០៣ ខែ មិថុនា ឆ្នាំ ២០១២ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវកាលបរិច្ឆេទនៃការបោះឆ្នោតនេះ នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ។

**មាត្រា ពីរ._**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣៩ល. ១១០៧. ៤៥៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ ៦០៧ ចុ.ល

ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ២០១១

អគ្គលេខាធិការ [illegible]

**ឃុន ជិនកេន**

# ព្រះរាជក្រម

នស / រកម / ០៧១១ / ០១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១៦/០០៤/២០១១ កបធ.ច ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
# ស្តីពី
# វិសោធនកម្មច្បាប់ស្តីពី
# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រាមួយ.–**

ត្រូវបានកែប្រែមាត្រា ១០៩ មាត្រា ១៣១ និងមាត្រា ១៣៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ មាត្រា ៣២ថ្មី មាត្រា ៥៤ថ្មី មាត្រា ៥៦ថ្មី មាត្រា ៥៩ថ្មី មាត្រា ៦១ថ្មី មាត្រា ៦២ថ្មី មាត្រា ៦៤ថ្មី មាត្រា ៦៥ថ្មី មាត្រា ៦៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ និងមាត្រា ៤៩ ថ្មី(ពីរ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដូចតទៅ:

**មាត្រា ៣២.– ថ្មី(ពីរ)**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបំពេញការងាររបស់ខ្លួន រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរ ។

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ហុកសិប (៦០)ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបន្តការងាររបស់ខ្លួនរហូតដល់មានការតែងតាំងថ្មី ។

ក្នុងករណីខកខានមិនបានរៀបចំសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមចំនួនសមាជិកដូចបានបញ្ញត្តក្នុងវាក្យខណ្ឌទី ៣ មាត្រា ១៣ថ្មី(ពីរ)នៃច្បាប់នេះ សមាសភាពនៃគណៈ-

កម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវបន្តការងារ និងមានសមត្ថកិច្ចចាត់ចែងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតផ្សេងទៀតតាមច្បាប់តម្រូវ ។

**មាត្រា ៤៩.- ថ្មី(បី)**

សៀវភៅបញ្ជីនេះ ត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ ហើយត្រូវថតចម្លងផ្លូវការមួយច្បាប់ រក្សាទុកនៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវធ្វើចាប់ពីថ្ងៃទី ០១ ខែ តុលា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចកាលបរិច្ឆេទ និងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្សេងពីនេះ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតយ៉ាងយូរសាមសិប(៣០)ថ្ងៃ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឬ ប្រធានសក្តិ ឬ អសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងពីនេះ ។

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបង្កើតថ្មីដែលត្រូវកែប្រែព្រំប្រទល់ តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌដែលចែងក្នុងច្បាប់នេះ និងបទបញ្ជា និងនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៥៤.- ថ្មី(ពីរ)**

**ក**-ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋត្រូវទៅបង្ហាញខ្លួននៅសាលាឃុំ សង្កាត់របស់ខ្លួន ឬ ទី កន្លែងណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ពេលបង្ហាញខ្លួន ប្រជាពលរដ្ឋត្រូវ :

-បង្ហាញអត្តសញ្ញាណរបស់ខ្លួនដល់ស្មៀនឃុំ សង្កាត់ ។

-មានសិទ្ធិបោះឆ្នោតស្របតាមមាត្រា ៥០ ថ្មី នៃច្បាប់នេះ ។

-មិនទាន់បានចុះឈ្មោះ ឬ បានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬ មិនទាន់បាន ចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់ ។

ក្នុងករណីដែលមានប្រជាពលរដ្ឋដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដែលបានផ្លាស់ទីលំនៅចេញទៅឃុំ សង្កាត់ផ្សេង ស្មៀនឃុំ សង្កាត់ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក ហើយក្នុង

រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៤៩ថ្មី(បី) នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ត្រូវលុបឈ្មោះប្រជាពលរដ្ឋទាំងនោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។

ចំពោះប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះពីមុនមក ដែលទើបដល់អាយុត្រូវបោះឆ្នោត ដែលបានផ្លាស់ទីលំនៅចូលថ្មី ស្មៀនឃុំ សង្កាត់ ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក ហើយក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋទាំងនោះត្រូវបំពេញល័ក្ខខ័ណ្ឌសម្រាប់ការចុះឈ្មោះដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ និងវាក្យខ័ណ្ឌទី ២ នៃមាត្រានេះ ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ឱ្យធ្វើការចុះឈ្មោះចល័តស្របតាមបទបញ្ជានិងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**ខ**-ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយ ដូចខាងក្រោម:

-លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

-អត្តសញ្ញាណប័ណ្ណដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា ដោយមានបិទរូបថតជាសំគាល់ ។

-សៀវភៅគ្រួសារ ។

ប្រជាពលរដ្ឋដែលមកបង្ហាញខ្លួន អាចកំណត់អត្តសញ្ញាណរបស់ខ្លួនបាន ដោយការធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីររូបក្នុងឃុំ សង្កាត់នោះ ធ្វើឡើងនៅចំពោះមុខមេឃុំ ចៅសង្កាត់ ឬ ចំពោះមុខជំទប់ ចៅសង្កាត់រង ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមាន ដោយបញ្ជាក់ថាអ្នកសុំចុះឈ្មោះនោះពិតជាមនុស្សដូចដែលសាមីខ្លួនបានបញ្ជាក់អះអាងមែន រួចហើយត្រូវយកលិខិតបញ្ជាក់នោះមកបង្ហាញស្មៀនឃុំ សង្កាត់ភ្លាម ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត ។

**គ**-ដើម្បីបញ្ជាក់ថាខ្លួនជាប្រជាពលរដ្ឋខ្មែរ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយក្នុងចំណោមឯកសារដូចខាងក្រោម:

-លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលបានផ្តល់ឱ្យអនុលោមទៅតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៣៦ អនក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីអត្ត-សញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

-អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬ កងយោធពលខេមរភូមិន្ទ ឬ នគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

-ឆាយារបស់ព្រះសង្ឃ ។

-កស្តុតាងដែលបង្ហាញថា ឈ្មោះរបស់អ្នកសុំចុះឈ្មោះមាននៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ និងសៀវភៅបញ្ជីបោះឆ្នោតរបស់ឃុំ សង្កាត់ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

-សំបុត្រកំណើតដែលមានបញ្ជាក់ពីសញ្ជាតិខ្មែរ ។

-លិខិតបញ្ជាក់ថាជាប្រជាពលរដ្ឋខ្មែរ ដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា ។

-លិខិតបញ្ជាក់ ឯកសារ ឬ សេចក្តីសម្រេចស្ថាពររបស់តុលាការដែលបញ្ជាក់ថា ឪពុក ឬ ម្តាយរបស់អ្នកសុំចុះឈ្មោះជាប្រជាពលរដ្ឋខ្មែរ និងឯកសារដែលបង្ហាញថាអ្នកសុំចុះឈ្មោះ គឺជាកូនរបស់ឪពុក ឬ ម្តាយនោះ ។

-ឯកសារជាផ្លូវការបង្ហាញថា អ្នកសុំចុះឈ្មោះកើតនៅក្នុងប្រទេសកម្ពុជា ហើយ ឪពុក និង ម្តាយបរទេសរបស់ជននោះ ក៏កើត និងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាដែរ និងឯកសារជាផ្លូវការ ដែលបង្ហាញថាអ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុក និងម្តាយនោះ ។

**ឃ**-ដើម្បីបញ្ជាក់ថាខ្លួនមានអាយុយ៉ាងតិច ១៨ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយដូចខាងក្រោម:

-ឯកសារណាមួយដូចមានចែងក្នុងមាត្រា ៥៤ថ្មី (ពីរ) **ខ** និង**គ** នៃច្បាប់នេះ ដែលមានបញ្ជាក់ពីអាយុ ឬ ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកសុំចុះឈ្មោះ ឬ លិខិតធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីរ (២) រូប ក្នុងឃុំ សង្កាត់នោះ ធ្វើឡើងចំពោះមុខមេឃុំ ចៅសង្កាត់ ដោយបញ្ជាក់ថាអ្នកសុំចុះឈ្មោះ នោះពិតជាមានអាយុ១៨ឆ្នាំ យ៉ាងតិច គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រប្រាកដមែន ។

**ង**-ដើម្បីបញ្ជាក់ថាខ្លួនពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយដូចខាងក្រោម:

-ឯកសារទាំងឡាយដូចមានចែងក្នុងមាត្រា ៥៤ថ្មី(ពីរ) **ខ គ** និង **ឃ** នៃច្បាប់នេះ ហើយដែលបញ្ជាក់ថាអ្នកសុំចុះឈ្មោះពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ឬ លិខិតបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់ថាសាមីខ្លួនពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ។

**ច**-ក្នុងករណីដែលប្រជាពលរដ្ឋមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៥៤ថ្មី (ពីរ) **ខ គ ឃ** និង **ង** នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ត្រូវ:

-ចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត ។

-កត់ឈ្មោះប្រជាពលរដ្ឋនោះចូលក្នុងសៀវភៅបញ្ជីបោះឆ្នោត ។

-ចេញបង្កាន់ដៃបញ្ជាក់អំពីការចុះឈ្មោះជូនសាមីខ្លួន ។

-បញ្ជាក់ប្រាប់ប្រជាពលរដ្ឋអំពីការិយាល័យបោះឆ្នោតដែលប្រជាពលរដ្ឋនោះ ត្រូវទៅបោះឆ្នោត ។

ចំពោះប្រជាពលរដ្ឋណាដែលមានឈ្មោះក្នុងសៀវភៅបញ្ជីបោះឆ្នោតរួចហើយ ស្មៀនឃុំ សង្កាត់គ្រាន់តែពិនិត្យភស្តុតាងនៃការចុះឈ្មោះរបស់ជននោះ ប្រសិនបើជននោះមិនស្ថិតក្នុងករណីណាមួយដូចមានចែងក្នុងវាក្យខ័ណ្ឌទី ៣ មាត្រា ៥៤ថ្មី (ពីរ) **ក** នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ត្រូវធ្វើបច្ចុប្បន្នភាពឈ្មោះរបស់ជននោះចូលក្នុងបញ្ជីបោះឆ្នោត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៦._ ថ្មី(ពីរ)**

ស្មៀនឃុំ សង្កាត់ បន្ទាប់ពីបានសុំយោបល់ពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រចាំការមើលការខុសត្រូវ អាចបដិសេធការចុះឈ្មោះដល់អ្នកមកចុះឈ្មោះ ក្នុងករណីមានភស្តុតាងបញ្ជាក់ថាជននោះពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមមាត្រា ៥០ថ្មី មាត្រា ៥៤ថ្មី (ពីរ) **ក ខ គ ឃ** និង **ង** នៃច្បាប់នេះ ។

ក្នុងករណីដែលស្មៀនឃុំ សង្កាត់បដិសេធការចុះឈ្មោះបោះឆ្នោតរបស់ប្រជាពលរដ្ឋ ស្មៀនឃុំ សង្កាត់ត្រូវៈ

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធមួយច្បាប់ជូនសាមីខ្លួន ។

-ផ្តល់ព័ត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា ៥៧ថ្មី នៃច្បាប់នេះ សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ា ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលបី(៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធមួយច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរយៈលេខាធិការដ្ឋាន គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៥៩._ ថ្មី(ពីរ)**

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់យល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់ឱ្យស្មៀនឃុំ សង្កាត់ អនុវត្តការចុះឈ្មោះតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥៤ថ្មី (ពីរ) **ច** នៃច្បាប់នេះ ។

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវៈ

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធមួយច្បាប់ជូនសាមីខ្លួន ។

-ផ្តល់ព័ត៌មានជូនសាមីខ្លួនថាអនុលោមតាមមាត្រា ៦០ថ្មី នៃច្បាប់នេះ សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ា ជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលប្រាំ(៥)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធមួយច្បាប់ ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈលេខាធិការដ្ឋាន គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៦១._ ថ្មី(ពីរ)**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលប្រាំ(៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញសេចក្តីសម្រេចទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីចាត់ឱ្យស្មៀនឃុំ សង្កាត់ ចុះឈ្មោះអ្នកដែលត្រូវបានបដិសេធ ដោយអនុវត្តតាមល័ក្ខខ័ណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៥៤ថ្មី (ពីរ) **ច** នៃច្បាប់នេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវៈ

-បំពេញបែបបទនៃការបដិសេធដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធនេះមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ។

-ផ្តល់ព័ត៌មានទៅសាមីខ្លួនថាអនុលោមតាមមាត្រា ៦២ថ្មី (ពីរ)នៃច្បាប់នេះ សាមីខ្លួន ឬ តំណាងអាចប្តឹងតវ៉ា ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលប្រាំ(៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសេចក្តីចម្លងនៃការបដិសេធនេះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

## មាត្រា ៦២.- ថ្មី(ពីរ)

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួន ត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬ តំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលដប់ (១០) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រម ឬមិនយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវៈ

-ចេញសេចក្តីសម្រេចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬ បដិសេធឈ្មោះអ្នកដែលមានបញ្ហា ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីសម្រេចយល់ព្រម ឬ បដិសេធនេះមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ តំណាង ។

ប្រសិនបើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញតម្រូវឱ្យចុះឈ្មោះអ្នកដែលមានបញ្ហា គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចុះឈ្មោះបោះឆ្នោតអ្នកដែលមានបញ្ហានោះ តាមល័ក្ខខ័ណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៥៤ថ្មី(ពីរ) **ច** នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនោះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា ៦៤.- ថ្មី(ពីរ)

ក្នុងរយៈពេលប្រាំ(៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ជនណាក៏ដោយក៏អាចប្តឹងតវ៉ាជាលាយល័ក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ខ្លួន ពីការបាត់បង់ឈ្មោះ ឬ ជំទាស់ការចុះឈ្មោះ ឬ ការរក្សាទុកឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃជនណាម្នាក់ដែលខ្លួនមានភស្តុតាងបញ្ជាក់ថា:

-ជននោះពុំមានល័ក្ខខ័ណ្ឌត្រឹមត្រូវ គ្រប់គ្រាន់តាមមាត្រា៥០ថ្មី និងមាត្រា ៥៤ថ្មី(ពីរ)នៃច្បាប់នេះ ។

- ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង។

-ជននោះបានមកចុះឈ្មោះ មានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែជននោះ គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

-ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែកត់ត្រាមិនច្បាស់លាស់ ។

អ្នកប្តឹងតវ៉ាត្រូវបង្ហាញភស្តុតាងជាឯកសារណាមួយទៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

អ្នកប្តឹងជំទាស់ ត្រូវផ្តល់ព័ត៌មានបន្ថែម ក្នុងករណីមានការស្នើសុំពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល ការប្តឹងដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ មានរយៈពេលដប់ (១០)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

## មាត្រា ៦៥.- ថ្មី(ពីរ)

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ា ឬជំទាស់ ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬ ជំទាស់នេះជាការត្រឹមត្រូវ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យស្មៀនឃុំ សង្កាត់ឱ្យចុះឈ្មោះ អ្នកដែលមានបញ្ហានោះក្នុងបញ្ជីបោះឆ្នោត ឬ លុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើអ្នកតវ៉ា ឬ ជំទាស់ ឬ អ្នកដែលមានបញ្ហាពុំពេញចិត្តនឹងការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជននោះ ឬ តំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលប្រាំ(៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចលើបណ្តឹងតវ៉ា ឬ ជំទាស់នោះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នោះជាការត្រឹមត្រូវ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ការឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ចុះឈ្មោះអ្នកដែលមានបញ្ហានោះក្នុងបញ្ជីបោះឆ្នោត តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥៤ថ្មី (ពីរ) **ច** នៃច្បាប់នេះ ឬ លុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

ប្រសិនបើអ្នកតវ៉ា ឬ អ្នកជំទាស់ពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬ តំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលប្រាំ(៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ៦៦.– ថ្មី(ពីរ)

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ា ឬជំទាស់នោះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលដប់(១០) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬ ជំទាស់នោះជាការត្រឹមត្រូវ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវៈ

-ចេញសេចក្តីសម្រេចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬ បដិសេធឈ្មោះអ្នកប្តឹងតវ៉ា ឬ អ្នកជំទាស់ ឬ អ្នកដែលមានបញ្ហា ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីយល់ព្រម ឬ បដិសេធនេះមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬអ្នកជំទាស់ ឬ អ្នកដែលមានបញ្ហា ។

ប្រសិនបើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ តម្រូវឱ្យចុះឈ្មោះអ្នកប្តឹងតវ៉ា ឬអ្នកដែលមានបញ្ហា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ការឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ចុះឈ្មោះជននោះតាមល័ក្ខខ័ណ្ឌចុះឈ្មោះបោះឆ្នោតដូចមានចែង ក្នុងមាត្រា ៥៤ថ្មី (ពីរ) **ឆ** នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនោះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

## មាត្រា ១០៩.– ថ្មី

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវប្រមូលកំណត់ហេតុ និងឯកសារទាំងអស់ពីគ្រប់គណៈកម្មការការិយាល័យបោះឆ្នោត រួចធ្វើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន។ កំណត់ហេតុនេះ ត្រូវធ្វើជាបួនច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មួយច្បាប់ផ្ញើជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត មួយច្បាប់បិទផ្សាយនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងមួយច្បាប់ទៀតទុកជាឯកសារ ។

ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬ ពីភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតណាមួយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបើកការប្រជុំសម្រេចជាសាធារណៈជាបន្ទាន់។

ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬ តំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតជាបន្ទាន់។

**មាត្រា ១៣១.- ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀលទៅដប់លាន(១០.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(៥)ឆ្នាំ ចំពោះជនណា ឬគណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ថ្មី ឬ មាត្រា ៧៦ នៃច្បាប់នេះ ។

**មាត្រា ១៣៣.- ថ្មី**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧២ នៃច្បាប់នេះ ។ ក្នុងករណីដែលនៅពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេលប្រាំ(៥)ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០) រៀល ដល់ដប់លាន (១០.០០០.០០០) រៀល ។

**មាត្រា ពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៧១១/៥៤៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខៈ ៦០៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ជិនគេន

10/06

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ:

សមាជិក សមាជិកានៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំនួន ០៦រូប ដែលមានគុណបំណាច់

និងស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ លើវិស័យយុត្តាធិការ

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោកជំទាវ **ជា លាង**

២-ឯកឧត្តម **យូ ប៊ុនឡេង**

៣-ឯកឧត្តម **អ៊ុក សាវុធ**

៤-ឯកឧត្តម **គង់ ស្រ៊ីម**

៥-ឯកឧត្តម **ជីវ កេង**

៦-ឯកឧត្តម **យ៉េត ចរិយា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១១០៦.៥៧៩

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១១

លេខ: ៥៧៦ . ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៧២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

១ - ឯកឧត្តម ជា ថោយ

២ - ឯកឧត្តមឧកញ៉ា ស្វ ជួងហួរ

៣៧៧. ១១០៦. ៥៩១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

លេខ: ៦០១ ច.ល
ផ្ញើចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ប៉ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា និងសប្បុរសជន ចំនួន ២៣ រូប
បានបំពេញការងារសំខាន់ៗ និងបានចូលរួមកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

- ឯកឧត្តម **នាវ អ៊ុនអ៊ីវ**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម **លាង សេង** ៣- លោក **ឃិន ខេមរា**
២- លោកជំទាវ **ជា សុផាកន្នី** ៤- លោកស្រី **ជា ជុតិម៉ា**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- ឯកឧត្តម **លឹម ហួរ** ៣- លោក **ញ៉ុក ថុល**
២- លោកជំទាវ **ទាន់ ជិនណា** ៤- លោក **កន សុភឿន**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោក **ដួង សំអូន** ៣- លោក **សេង ម៉េងឡុង**
២- លោក **ប៊ូ សុវណ្ណារ៉េត** ៤- លោក **ជា ប៉ោ**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- លោក **ប៉ុល វិបូ** ៦- លោក **ម៉ុង ធិរិទ្ធ**
២- លោក **ហ៊ុន ឈុនហៀង** ៧- លោកស្រី **ស្រេង សុគន្ធា**
៣- លោក **សុខ លី** ៨- លោក **ជូ សៀងគុង**
៤- លោក **ញាណ សុមុន្នី** ៩- លោក **លឹម សុងចេង**
៥- លោក **នាវ យុនម៉ឹង** ១០- លោក **ពៅ ម៉ុក**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.១១០៦.៥៩៤

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

លេខៈ ៥៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១- លោកជំទាវ **ឯក សំបុល** មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម **ចិន ដានី** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រ.ល. ១១០៦.៥៩៩

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

លេខៈ ៥៧៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី[illegible] ខែ មិ[illegible] ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម ៖

**ក-ថ្នាក់ឧត្តមសេនីយ៍ទោ**

- លោកឧត្តមសេនីយ៍ត្រី **ស៊ិន សារិទ្ធ** អត្តលេខ ០៥៣៦

**ខ-ថ្នាក់ឧត្តមសេនីយ៍ត្រី**

- លោកវរសេនីយ៍ឯក **លន់ ចន្ធា** អត្តលេខ ០១០៥៧ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.១១០៦.៥០២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

លេខ ៥៧៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១១

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ឈិន ចន** (CHEN JOHN) ជនជាតិចិន សញ្ញាតិអាមេរិក កើតថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧០ នៅខេត្តហ្វ៊ូគៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.១១០៦.៦០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

លេខ: ៥៦៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃ៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គីម ជូ ដុក** (KIM JOO DEOG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៦០ នៅខេត្តហ្គ័ងជី សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **គីម តារា** (KIM TARA)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរជ.១១០៦.៦០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១១

លេខៈ ៥៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ចំនួន ១១រូប
ដែលមានគុណបំណាច់ និង ស្នាដៃចំពោះជាតិមាតុភូមិ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ឡៅ សុខារម្ភ ៣- ឯកឧត្តម ហាស់ ម៉េងហុង
២- ឯកឧត្តម គួច ប៊ុនហួរ

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- ឯកឧត្តម ឱុច សារ៉េត ៣- ឯកឧត្តម យ៉ាន់ ទ៉ាន់យ៉េង
២- ឯកឧត្តម ហៃ សេង

គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១- ឯកឧត្តម ណាំ លីណាល់ ៤- លោក កាន់ ឫទ្ធី
២- ឯកឧត្តម ឡៅ សិទ្ធី ៥- លោក សុខ សំអាង
៣- លោក ហេង សិទ្ធី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១១០៦.៦០៥

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

លេខ: ៥៦៩ ច.ល
បានថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យ៉ុន ជិនអេន

# ព្រះរាជក្រឹត្យ

នស / រកត / ០៦១១ / ៥៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាប័ត្រជូនមន្ត្រីរាជការចំនួន ០៤រូប ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម÷

| ល.រ | **គោត្តនាម និងនាម** | **ភេទ** | **ថ្នាក់ចាស់** | **ថ្នាក់ថ្មី** |
|---|---|---|---|---|
| ១ | **ឈរ ថាណារ៉ាត** | ប | ថ្នាក់លេខ ២ | ថ្នាក់លេខ ១ |
| ២ | **សុខ ឡេងមុំរ៉ា** | ស | ថ្នាក់លេខ ៣ | ថ្នាក់លេខ ២ |
| ៣ | **ស្វួង លាងហៃ** | ប | ថ្នាក់លេខ ៣ | ថ្នាក់លេខ ២ |
| ៤ | **តាយ អ៊ាន់ឡើង** | ស | ថ្នាក់លេខ ៥ | ថ្នាក់លេខ ៤ |

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល. ១១០៦. ៦០៦

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១*

លេខៈ ៥៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនរតន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រត្នខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ប្រគេន

ព្រះតេជគុណ សៀម សុខណ្ណជា

ដែលបានជួយកសាងសមិទ្ធផលនានា នៅវត្តជ្រៃបិទមាស ស្ថិតនៅក្នុងសង្កាត់សួង
ក្រុងសួង ខេត្តកំពង់ចាម

*ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១*

*ពរល. ១១០៦. ៦០៧*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខៈ ៥៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស

**សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន**

ថ្នាក់ **មហាសេរីវឌ្ឍន៍**

ចំពោះ

ឯកឧត្តម **ខួន ស្រេង**

បានចូលរួមជួយកសាងសមិទ្ធផលនានា នៅឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល. ១១០៦.៦០៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១*

លេខៈ ៥៧១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

តែងតាំង

ឯកឧត្តម **សុខ ចំរើន**

ជា

**ឧកញ៉ា**

៣រណ.១១០៦.៦០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១*

លេខៈ ៥៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក **សុខ វណ្ណា**

ជា

**ឧកញ៉ា**

៣រល-១១០៦.៦១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

លេខ: ៥៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនអេន

នស/រកត/០៦១១/៦០០

# ព្រះរាជក្រឹត្យ
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១

## ត្រាស់បង្គាប់

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត ក្រុមប្រឹក្សាជាតិភាសាខ្មែរ សរសេរកាត់ថា "**ក.ជ.ភ.ខ.**" ដែលជាយន្តការជាតិស្ថិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអភិរក្សនិងអភិវឌ្ឍការប្រើភាសានិងអក្សរខ្មែរប្រកបដោយនិរន្តរភាព ព្រមទាំងរក្សាបាននូវអត្តសញ្ញាណជាតិខ្មែរ។

## ជំពូកទី២
## សមាសភាពរបស់ ក.ជ.ភ.ខ.

**មាត្រា ២.-**

**ក.ជ.ភ.ខ.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| - នាយករដ្ឋមន្ត្រី | | គរុគណ |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | | ប្រធានកិត្តិយស |
| - ឥស្សរជនជំនាញនិងមានបទពិសោធខាងអក្សរសាស្ត្រ | មួយរូប | ប្រធាន |
| - ប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា | | អនុប្រធាន |
| - ឥស្សរជនជំនាញខាងអក្សរសាស្ត្រ | មួយចំនួន | អនុប្រធាន |
| - តំណាងមួយរូបពីក្រសួង ស្ថាប័នពាក់ព័ន្ធ | មួយចំនួន | សមាជិក |
| - ឥស្សរជនជំនាញខាងអក្សរសាស្ត្រ | មួយចំនួន | សមាជិក |
| - ឥស្សរជនជំនាញឯកទេស | មួយចំនួន | សមាជិក |
| - តំណាងសមាគមអ្នកនិពន្ធខ្មែរ | មួយរូប | សមាជិក |
| - អគ្គលេខាធិការ **ក.ជ.ភ.ខ.** | | សមាជិក។ |

សមាសភាព **ក.ជ.ភ.ខ.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា ៣.-**

**ក.ជ.ភ.ខ.** អាចមានទីប្រឹក្សាមួយចំនួនតាមការចាំបាច់។

## ជំពូកទី៣
## ភារកិច្ចរបស់ ក.ជ.ភ.ខ.

**មាត្រា ៤.-**

**ក.ជ.ភ.ខ.** មានភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយជាតិនៃភាសានិងអក្សរខ្មែរ
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ
- ពិនិត្យនិងសម្រេច ឲ្យមានការឯកភាពនូវពាក្យនិងបច្ចេកសព្ទដែលបានប្រើក្នុងភាសាខ្មែររួចមកហើយ
- កំណត់ការសរសេរ ការអាន និង និយមន័យឲ្យមានការឯកភាពក្នុងភាសាខ្មែរ
- បង្កើតពាក្យថ្មី និង សម្រេចអំពីការខ្ចីពាក្យ
- ត្រួតពិនិត្យការប្រើប្រាស់ភាសានិងអក្សរខ្មែរ
- ដាក់ជូនប្រមុខរាជរដ្ឋាភិបាលប្រកាសឲ្យប្រើជាសាធារណៈនូវលទ្ធផលនៃការកំណត់ការប្រើភាសានិងអក្សរខ្មែរ

- បង្ក្រង និង ផ្សព្វផ្សាយភាសានិងអក្សរខ្មែរតាមមធ្យោបាយផ្សេងៗដែលមានសិក្ខាសាលាផង
- សហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និង រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីមានវិធានការសមស្របចំពោះការប្រើភាសានិងអក្សរខ្មែរដែលបានកំណត់រួចហើយឲ្យមានប្រសិទ្ធភាព
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាពាក់ព័ន្ធនឹងការប្រើភាសា និង អក្សរខ្មែរ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## កិច្ចដំណើរការការងាររបស់ ក.ជ.ភ.ខ.

**មាត្រា ៥.-**

**ក.ជ.ភ.ខ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធាន **ក.ជ.ភ.ខ.** មានសិទ្ធិអញ្ជើញតំណាងក្រសួង និង ស្ថាប័នពាក់ព័ន្ធ ជាថ្នាក់ដឹកនាំ និង ថ្នាក់បច្ចេកទេសឲ្យមកចូលរួមប្រជុំដើម្បីជួយបំភ្លឺ និង ផ្តល់ព័ត៌មានបន្ថែមតាមការចាំបាច់។

**មាត្រា ៦.-**

**ក.ជ.ភ.ខ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ**ក.ជ.ភ.ខ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៧.-**

**ក.ជ.ភ.ខ.**មានគណៈកម្មការបច្ចេកទេសសម្រាប់កិច្ចដំណើរការការងារតាមការចាំបាច់។

សមាសភាពនិងតួនាទីភារកិច្ចរបស់គណៈកម្មការបច្ចេកទេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ៨.-**

**ក.ជ.ភ.ខ.** មានសញ្ញា និង ត្រាដោយឡែករបស់ខ្លួន។

**មាត្រា ៩.-**

របៀបរបបបំពេញការងាររបស់ **ក.ជ.ភ.ខ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១០.-**

ប្រធាន អនុប្រធាន សមាជិក និង ទីប្រឹក្សា **ក.ជ.ភ.ខ.** គណៈកម្មការបច្ចេកទេស ទទួលប្រាក់របបប្រជុំនិងស្រាវជ្រាវតាមការកំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា ១១.-**

**ក.ជ.ភ.ខ** ត្រូវប្រើវចនានុក្រមខ្មែររៀបរៀងដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ឆ្នាំ១៩៦៧ ជាគោល។

## ជំពូកទី៥
## ប្រភពធនធានរបស់ ក.ជ.ភ.ខ.

**មាត្រា ១២.-**

**ក.ជ.ភ ខ.** មានប្រភពធនធានបានមកពី ៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- អំណោយ និង វិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍ជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និង សប្បុរសជននានា
- ជំនួយឥតសំណងផ្សេងៗ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១១

ទរល. ១១០៦. ៦១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៥៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ចិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ
## របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ សរសេរកាត់ថា អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ដែលជាសេនាធិការសម្រាប់កិច្ចដំណើរការការងាររបស់ **ក.ជ.ភ.ខ.**។

## ជំពូកទី២

## ភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.**មានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំផែនការការងារនិងសម្របសម្រួលដំណើរការងារជូន **ក.ជ.ភ.ខ.**
- រៀបចំយន្តការត្រួតពិនិត្យនិងតាមដានការប្រើភាសានិងអក្សរខ្មែរ
- រៀបចំយន្តការសម្រាប់បណ្តុះបណ្តាលការប្រើភាសានិងអក្សរខ្មែរ
- រៀបចំយន្តការចងក្រងនិងផ្សព្វផ្សាយភាសានិងអក្សរខ្មែរ
- គ្រប់គ្រងកិច្ចការរដ្ឋបាលនៃ **ក.ជ.ភ.ខ.**
- បំពេញការងារហិរញ្ញវត្ថុជូន **ក.ជ.ភ.ខ.**
- រៀបចំផែនការបណ្តុះបណ្តាលមន្ត្រីលេខាធិការដ្ឋាន ដើម្បីពង្រឹងនិងបង្កើនសមត្ថភាពការងារ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពនិងលទ្ធផលការងារជូន **ក.ជ.ភ.ខ.**
- ជួយសម្រួលការងារស្រាវជ្រាវជូន **ក.ជ.ភ.ខ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

## ជំពូកទី៣

## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។ អគ្គលេខាធិការរង **ក.ជ.ភ.ខ.** បំពេញភារកិច្ចតាមការបែងចែកការងាររបស់អគ្គលេខាធិការ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

- ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
- ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល

- ផ្នែកតាមដាននិងត្រួតពិនិត្យ។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.**ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ផ្នែកនីមួយៗ ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធានផ្នែកត្រូវតែងតាំងដោយអនុក្រឹត្យនិងអនុប្រធានផ្នែកត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ៦.-**

មន្ត្រីអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ ដែលមកពីក្រសួងនិងស្ថាប័ននានា ឬបញ្ញវន្តដែលមានសមត្ថភាពខ្ពស់។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** អាចមានបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយការងារ។

មន្ត្រីដែលមិនទទួលប្រាក់បៀវត្ស ទទួលប្រាក់ឧបត្ថម្ភសម្រាប់បំពេញការងារជូន **ក.ជ.ភ.ខ.** តាមការស្នើសុំរបស់ប្រធាន **ក.ជ.ភ.ខ.**។

## ជំពូកទី៤
## ភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ៧.-**

ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុមានភារកិច្ច ដូចខាងក្រោម ៖

- ទទួលបន្ទុកការងារបុគ្គលិកនិងការងារពិធីការ
- ធានាប្រសិទ្ធភាពនិងនិរន្តរភាពនៃដំណើរការរដ្ឋបាល
- រៀបចំគ្រប់គ្រងសំណុំលិខិតរដ្ឋបាលនិងទុកដាក់ឯកសាររដ្ឋបាលគ្រប់ប្រភេទ
- សហការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាពាក់ព័ន្ធនឹងការប្រើភាសានិងអក្សរខ្មែរ
- ធ្វើផែនការរួមរបស់ **ក.ជ.ភ.ខ.**
- ធ្វើទំនាក់ទំនងនិងសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីសម្រួលការងាររបស់ **ក.ជ.ភ.ខ.**
- ការពារសន្តិសុខ សណ្តាប់ធ្នាប់ រក្សាសុវត្ថិភាពសម្ភារៈនិងអនាម័យ ក្នុងបរិវេណអគ្គលេខាធិការដ្ឋាន
- សហការបូកសរុបរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ
- ធ្វើកំណត់ហេតុរាល់អង្គប្រជុំរបស់ **ក.ជ.ភ.ខ.**
- ទទួលខុសត្រូវលើផ្នែកហិរញ្ញវត្ថុនិងផ្គត់ផ្គង់
- រៀបចំគម្រោងថវិកា គម្រោងសម្ភារៈបរិក្ខារ និង មធ្យោបាយការងារផ្សេងៗ
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ និងរាល់ចំណូល ចំណាយរបស់ **ក.ជ.ភ.ខ.**
- បូកសរុបរបាយការណ៍ថវិការបស់ **ក.ជ.ភ.ខ.**

- ទទួលខុសត្រូវថែរក្សាបញ្ជីគណនេយ្យនិងបេឡា
- ធ្វើទំនាក់ទំនងលើបញ្ហាថវិកាជាមួយទីស្តីការគណៈរដ្ឋមន្ត្រី
- ធ្វើរបាយការណ៍សកម្មភាពនិងលទ្ធផលការងារតាមការកំណត់
- ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

**មាត្រា ៨.-**

ផ្នែកបោះពុម្ព ផ្សព្វផ្សាយ និងបណ្តុះបណ្តាល មានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំចងក្រងពាក្យដែល**ក.ជ.ភ.ខ.** បានអនុម័តនិងបោះពុម្ពជាព្រឹត្តិបត្រនិងសទ្ទានុក្រម
- ចែកផ្សាយព្រឹត្តិបត្រ សទ្ទានុក្រម និងឯកសារផ្សេងៗ ដែលបានបោះពុម្ព
- រៀបចំគេហទំព័រនិងបញ្ចូលទិន្នន័យដែលត្រូវផ្សព្វផ្សាយ
- សហការជាមួយប្រព័ន្ធផ្សព្វផ្សាយនានាមាន វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ជាដើម ដើម្បីធ្វើការផ្សព្វផ្សាយលទ្ធផលរបស់ **ក.ជ.ភ.ខ.**និងសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាលទាក់ទងនឹងភាសា អក្សរខ្មែរ ឲ្យបានទូលំទូលាយ
- រៀបចំយន្តការសម្រាប់សិក្ខាសាលា ផ្សព្វផ្សាយនិងបណ្តុះបណ្តាល ការប្រើភាសានិងអក្សរខ្មែរដល់អ្នកនិពន្ធ អ្នកសារព័ត៌មាន ពិធីករ ពិធីការិនី និងដល់សាធារណជនទូទៅ
- រៀបចំគម្រោងបោះពុម្ពផ្សាយនិងចាត់ចែងបោះពុម្ពផ្សាយអត្ថបទ
- រៀបចំគ្រប់គ្រងបណ្ណាល័យ
- ធ្វើរបាយការណ៍សកម្មភាពនិងលទ្ធផលការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

**មាត្រា ៩.-**

ផ្នែកតាមដាននិងត្រួតពិនិត្យ មានភារកិច្ច ដូចខាងក្រោម ៖

- តាមដាននិងត្រួតពិនិត្យការប្រើភាសានិងអក្សរខ្មែរ តាមផ្លាកផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ តាមទស្សនាវដ្តី ព្រឹត្តិបត្រ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន សៀវភៅ និងឯកសារផ្សេងៗទៀត
- ចូលរួមសហការស្រាយបំភ្លឺចម្ងល់របស់សាធារណជន លើការប្រើភាសានិងអក្សរខ្មែរ
- ប្រមូលនិងស្រង់ពីគ្រប់មជ្ឈដ្ឋាននិងគ្រប់តំបន់នូវទិន្នន័យទាក់ទងនឹងការប្រើភាសានិងអក្សរខ្មែរ ក្រោយពេលដែលរាជរដ្ឋាភិបាល បានប្រកាសឲ្យប្រើជាសាធារណៈ
- ធ្វើរបាយការណ៍សកម្មភាពនិងលទ្ធផលការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ......១៣៨.........អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១១
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ត.ខ.



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...១៣៥...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ , ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ.បក, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១** : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១០.០០០ លានរៀល (ដប់ពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) ជូនក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ទិញឧបករណ៍ សម្ភារៈបច្ចេកទេស សម្រាប់ដំណើរការផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ ក្នុងឆ្នាំ ២០១១-២០១៣ ។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ១៤០ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ សម្រាប់អាណត្តិទី ១

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ស្តីពីការបង្កើតខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ សម្រាប់អាណត្តិទី ១ មានចំនួន ១៩នាក់ ដោយអនុលោមទៅតាមមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១១

ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤១ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៤៨៨ ហិកតា**

**ស្ថិតនៅភូមិសាស្ត្រ ស្រុកជ័យសែន ខេត្តព្រះវិហារ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង ប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១: -**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៦.៤៨៨ ( ប្រាំមួយពាន់បួនរយប៉ែតសិបប្រាំបី) ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំគស្វូ ឃុំស្អាង និងឃុំពុទ្រា ស្រុកជ័យសែន ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ អាកាស្យា និងអំពៅ ដូចមានក្នុងផែនទី និងនិយាមកាលេខ ៣១៥ចលលផ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១១ របស់សាលាខេត្តព្រះវិហារ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២: -**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្រប តាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ផែនទី ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហេង ឈុង(ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី ស្ថិតនៅក្នុង ឃុំគសួ ឃុំស្អាង និងឃុំព្រហ្មទេព ស្រុកជ័យសែន ខេត្តព្រះវិហារ




និយាមការ ចំណុចកោងនៃក្បាលដី :

| Coor_x | Coor_y | N |
|---|---|---|
| 520000. | 1504248. | a |
| 516609. | 1504247. | b |
| 526570. | 1504703. | e |
| 520000. | 1507222. | d |
| 516423. | 1507166. | c |
| 523149. | 1499248. | h |
| 523360. | 1499778. | g |
| 523901. | 1499788. | f |

| Coor_x | Coor_y | N |
|---|---|---|
| 514821. | 1506644. | 1 |
| 514745. | 1507070. | 2 |
| 514334. | 1507575. | 3 |
| 518064. | 1510235. | 4 |
| 513730. | 1511574. | 5 |
| 518598. | 1510024. | 6 |
| 514412. | 1511742. | 7 |
| 518102. | 1509141. | 8 |
| 518721. | 1509322. | 9 |
| 514200. | 1512293. | 10 |
| 513661. | 1512081. | 11 |
| 514290. | 1511374. | 12 |

លេខ ៤១៧/០១១
បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
គសួ ថ្ងៃទី ... ខែ ០៤ ឆ្នាំ២០១១
មេឃុំ
ចាន់_ស្រី

លេខ ២២០
បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
ស្អាង ថ្ងៃទី ២២ ខែ ០៤ ឆ្នាំ២០១១
មេឃុំ
គោស_សិត

លេខ ១៥៤
បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
ព្រហ្មទេព ថ្ងៃទី ២២ ខែ ០៤ ឆ្នាំ២០១១
មេឃុំ
ជុំ_ចន្ទរ៉ុង

លេខ ១៦៤
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ជ័យសែន ថ្ងៃទី ... ខែ ... ឆ្នាំ២០១១
អភិបាលស្រុក
ថោង_សារឿន

លេខ ៣៤៥ កសក.ជឧ.កម
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី ២២ ខែ ៤ ឆ្នាំ២០១១
អភិបាលខេត្ត
អ៊ុំ ម៉ារ៉ា

លេខ ១១២ ជ.គ.ស.ក.ម
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី ២២ ខែ ០៤ ឆ្នាំ២០១១
ប្រធានមន្ទីរបរិស្ថាន
គឹម_ឆ្លើយ

លេខ ១០៩ ជនសស
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី ២២ ខែ ០៤ ឆ្នាំ២០១១
ប្រធានមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី
នង់_សោភ័ណ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៣៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការជូន គ្រឿងឥស្សរិយយស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- យោងតាមសំណើរបស់ សម្តេចចៅហ្វាវាំង គង់ សំអុល

## សម្រេច

**មាត្រា១** : បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការដែលមានស្នាដៃល្អ ខិតខំប្រឹងប្រែង លះបង់កំលាំងកាយ-ចិត្ត ក្នុងការបំពេញភារកិច្ច និងចំណាយថវិកា សំភារៈផ្ទាល់ខ្លួន ក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ប៉ុន្មានឆ្នាំកន្លងមក នៅក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ចំនួន ៤៥៨ រូប ដូចខាងក្រោម :

**ក- មេដាយ មាសការងារ :**

| | |
|---|---|
| ១- ឯកឧត្តម សុខ ម៉ាធឿន | ២- លោក ត្រាំ ឈ្វារ៉ាន់ |
| ៣- លោកស្រី ម៉ុត មុនីតាច | ៤- លោក អ៊ុំ គៀ |
| ៥- លោក សួច សេដ្ឋា | ៦- លោក សែម ផារី |
| ៧- លោក ស៊ូ គីមស៊ុ | ៨- លោក សុខ ចំរើន |
| ៩- លោក មាស ច័ន្ទ | ១០- លោកស្រី ខៀវ ចាន់ថា |
| ១១- លោក ឈុន ឈឿន | ១២- លោក សុខ សុផល |
| ១៣- លោក អោច និន្នារ៉ា | ១៤- លោក អ៊ុន អ៊ុន |
| ១៥- លោក កែ គឿន | ១៦- លោក កែ ធឿន |

១៧- លោក ឆាង ឆឿន
១៨- លោក ស៊ុំ ពិសិដ្ឋ
១៩- លោក នូ សារិទ្ធ
២០- លោក ស៊ៀន គឹមសាន
២១- លោក ម៉ូល សុភ័ក្រ
២២- លោក ឈុប សូរី
២៣- លោក ចាន់ ដារ៉ា
២៤- លោក ស៊ិន សារ៉ុន
២៥- លោក ប៉ែន សែត
២៦- លោក នួន សំណាង
២៧- លោក អង កុសល
២៨- លោក ស៊ីប ប៊ុនមឿង
២៩- លោកស្រី ស៊ិន សុខុនណា
៣០- កញ្ញា ខាញ សុខសម្ភារ
៣១- លោកស្រី លន់ ធិរៈមិថុនា
៣២- លោក វ័ន្ត តានិត
៣៣- លោក លី សុភ័ក្រ
៣៤- លោក ញ៉ៀម សិរិនឌី
៣៥- លោក មុំ ចន្ថុនៈ
៣៦- លោក ច្រឿង ផល្លីត្ន
៣៧- លោក នួន ស៊ីខេង
៣៨- លោក គួ ស៊ីម៉ន
៣៩- លោក ឌិត សុធី
៤០- លោកស្រី ហុង រ៉ានី
៤១- លោកស្រី ឌ៉ា លាងឆេង
៤២- លោកស្រី ខឹម វិចិត្រ
៤៣- លោកស្រី លី យុនអាន
៤៤- លោកស្រី តាន់ ម៉ាលី
៤៥- លោកស្រី ទេព សំអាត
៤៦- លោក សូ សុន្ទរ៉ា
៤៧- លោក យូ ណារិទ្ធ
៤៨- លោក មិន រ៉ាឌី
៤៩- លោក ស៊ុន ហួត
៥០- លោក ស៊ា សុជីវ័ន្ត
៥១- លោក លន់ ធីរៈវិចិត្រា
៥២- លោក ខេង សុមេធា
៥៣- លោក ម៉ែន ប៊ុណ្ណី
៥៤- លោក លាន់ ប៊ុនលឿន
៥៥- លោក ឆាយ លាភា
៥៦- លោក ជេដ្ឋា សុគន្ធ
៥៧- លោក សាត រិន
៥៨- លោក ឌង ភិរុណ
៥៩- លោក ព្រុំ ធិរៈ
៦០- លោកស្រី ខៀវ ស៊ីភា
៦១- លោក អ៊ឹម ទុតថា
៦២- លោក ខិល ប៊ូរ៉ា
៦៣- លោក ណាំ ស៊ារ
៦៤- លោក ពូ ម៉ានិត
៦៥- លោក ប៊ិន ចំរើន
៦៦- លោក យឹម ណារិទ្ធ
៦៧- លោក ផេង ហាន
៦៨- លោកស្រី សុខ ហៀង
៦៩- លោក ដោត ទេស
៧០- លោក អ៊ុន គឹមសាន្ត
៧១- លោក ហ៊ាន់ ចន្ថា
៧២- លោកស្រី មុិញ សារុំ
៧៣- លោក ចាន់ ថុន
៧៤- លោក អ៊ុង ឧចំដន
៧៥- លោក សុខ សារុន
៧៦- លោក ឌិន សំបូន
៧៧- លោក ម៉េង សឿន
៧៨- លោក ចាន់ សុខា
៧៩- លោក តៅ ហ៊ល
៨០- លោក ម៉ី ហឿន
៨១- លោក ច័ន្ទ សុខា
៨២- លោក សុខ ទ៉េង
៨៣- លោក អ៊ុង ប៊ិន
៨៤- លោក រស់ សេរីសោភ័ណ្ឌ
៨៥- លោក ស៊ុន ចណ្ណា
៨៦- លោក ស៊ុត ប៊ុនរិន
៨៧- លោក ហ៊ុន ម៉ូច
៨៨- លោក ហ៊ុម សំណាង

៨៩- លោក សុខ សារុំ
៩០- លោក ភុត សុផា
៩១- លោកស្រី ចាន់ សុខ
៩២- លោក ជាម សារ៉ែត
៩៣- លោក ស៊ុន សុខន
៩៤- លោក ចត់ សុម៉ាលី
៩៥- លោក សៀង សារ៉ាន់
៩៦- លោក មាន់ ឈុនវ៉ៃ
៩៧- លោក ច៉ន់ ឆាន
៩៨- លោក នេត រិន
៩៩- លោក នៅ សន្ធី
១០០- លោក អួន ម៉េត
១០១- លោក យុំ តើ
១០២- លោក ផុន ហ៊ុល
១០៣- លោក សែម សារឿន
១០៤- លោកស្រី ញឹម សុឃឿន
១០៥- លោក សៅ ជី
១០៦- លោក លីច ប៊ុនសុង
១០៧- លោក អ៊ុត ដន
១០៨- លោក ស្វ សម្បត្តិ
១០៩- លោក ថោ ស៊ុម៉េត
១១០- លោក គង់ គីម
១១១- លោក ប្រាក់ ចន្ធី
១១២- លោក សៅ សារឿន
១១៣- លោក រ៉ាយ សារ៉ែត
១១៤- លោក ផ្លុង សាប់
១១៥- លោក ឈិត ដឿន
១១៦- លោក សេត អ៊ុត
១១៧- លោកស្រី តើត សាវី
១១៨- លោក អ៊ូច ប៊ុនធឿន
១១៩- លោកស្រី ភឿត ហ៊ុង
១២០- លោក ឡឹត សំអឿន
១២១- លោក យង់ សំអេង
១២២- លោក ទេព សំអឿន
១២៣- លោក សែម សាត
១២៤- លោក ប៊ុន សុស
១២៥- លោក ប៊ីន ម៉ុន
១២៦- លោក ចិន ស៊ុម
១២៧- លោក ម៉ុង វិសាលសុខ
១២៨- លោក សន សុវណ្ណា
១២៩- លោក សុខ សុវណ្ណ
១៣០- លោក មុំ សំអឿន
១៣១- លោក សឹង ហាត
១៣២- លោក នុត ឡៃស៊ុម
១៣៣- លោក ប៊ុន ស៊ុង
១៣៤- លោក យង់ យ៉ន
១៣៥- កញ្ញា តែង យ៉ាន
១៣៦- លោកស្រី ភួង ថាវី
១៣៧- លោក ឯម ម៉ុន
១៣៨- លោក សួន ថួ
១៣៩- លោក ចិន សាន
១៤០- លោក ច័រ ធឿន
១៤១- លោក ញែម អឿន
១៤២- លោក ញ៉ុង ថុន
១៤៣- លោក ដៃ អាន
១៤៤- លោក ហុត រ៉ាន់
១៤៥- លោក ម៉ម ជីន
១៤៦- លោក ឆន សុន
១៤៧- លោក ឈិន ឆាំ
១៤៨- លោក វុត ជា
១៤៩- លោក ពុត បឿន
១៥០- លោក ចាន់ រុន
១៥១- លោក យឹន ខុន
១៥២- លោក ពៅ ឡួន
១៥៣- លោក ជី ស្លាត
១៥៤- លោក សួត ថួ
១៥៥- លោក សៅ គៀន
១៥៦- លោក មាស សាប់
១៥៧- លោក តែន ហេង
១៥៨- លោក ចិន គឿន
១៥៩- លោក ស៊ុំ ម៉ន
១៦០- លោក យុំ ឆើ

១៦១- លោក ស្វូស នួន
១៦២- លោក ជាម យឿន
១៦៣- លោក វ៉យ៉ម គឿង
១៦៤- លោក ឈឹម ខាត់
១៦៥- លោក រឹម សុខុន
១៦៦- លោក យត់ ចាន់ឫទ្ធិ
១៦៧- លោក ដួង ប៊ុម
១៦៨- លោក ថៃ ឈិន
១៦៩- លោក នង អ៊ិន
១៧០- លោក សៅ សុខ
១៧១- លោក មូល ត្រឹត
១៧២- លោក ញ៉ែម សឿន
១៧៣- លោក ញ៉ៀប ឡុន
១៧៤- លោក កែវ ថេន
១៧៥- លោក ចាន់ ស៊ុម
១៧៦- លោក ឡាយ ចេង
១៧៧- លោក ម៉ៅ ឃី
១៧៨- លោក ពេញ រិន
១៧៩- លោក គួន ឈឿន
១៨០- លោក រឹត ណង
១៨១- លោក ចត់ តៃ
១៨២- លោក ប៊ុត ម៉ៅ
១៨៣- លោក នង ជឿ
១៨៤- លោក សៅ ធិន
១៨៥- លោក ឆាន់ សែល
១៨៦- លោក ឆា ហ៊ីម
១៨៧- លោក ម៉ែន សុត
១៨៨- លោក ហ៊ីង រ៉ា
១៨៩- លោក កែវ ចិន្តា
១៩០- លោក អ៊ុន សំអាន
១៩១- លោក ខែត ហ៊ន
១៩២- លោក ឈួន ឃិត
១៩៣- លោក ចាន់ សៅធី
១៩៤- លោក ស្រី ហ៊ិន
១៩៥- លោក សាយ សុំ
១៩៦- លោក ស្វាយ ថៃ
១៩៧- លោក អ៊ុន ហ៊ិន
១៩៨- លោក លី លឹម
១៩៩- លោក សាត់ សារិន
២០០- លោក ឈឹម ពន
២០១- លោក ខាន់ ឆាត
២០២- លោក ហ៊ុល ម៉ាត
២០៣- លោក ជា សុខុប
២០៤- លោក យឹម ជឿន
២០៥- លោក តែ ហ៊ី
២០៦- លោក ទេព សុខុម
២០៧- លោក គឹម ភន
២០៨- លោក ម៉ែន នៅ
២០៩- លោក អ៊ូ ហួត

ខ- មេដាយ ប្រាក់ការងារ :

១- លោក សុខ ពុទ្ធិ
២- លោក ថា ស៊ីថេន
៣- លោក ម៉ែត ចឿន
៤- លោក ខែត ម៉ាន់ធី
៥- លោក ជួន សុផា
៦- លោក ប៊ុន សេរីវុទ្ធ
៧- កញ្ញា ឡាំ ចិចហួង
៨- លោក ទេព ឆាយ
៩- លោក ម៉ែត សំបិន
១០- លោក ឈឹម ឈៀង
១១- លោក ស្រស់ សម្បត្តិ
១២- លោក នុត យ៉ុន
១៣- លោក ឯល រ៉ុន
១៤- លោក គេង សុខុន
១៥- លោក ឡុច ចណ្ណនីន
១៦- លោក ចាន់ ណេន
១៧- លោក ចិន អាង
១៨- លោក គី សុងឆាយ

១៩- លោក ជេត សឿ
២០- លោក សែម ចាន់ថុល
២១- លោក អ៊ុច ចាន់ធឿន
២២- លោក មាស ចត
២៣- លោក នង ភីន
២៤- លោក គង់ សំអុល
២៥- លោក ជុន ស៊ីណាត
២៦- លោក ម៉ៅ ណារ៉ា
២៧- លោក ជា សារ៉ុន
២៨- លោក លី ហួត
២៩- លោក ហេង មួន
៣០- លោក រ័ត្ន ចណ្ណេត
៣១- លោក សួន ភឿន
៣២- លោក ខាត់ ប៉ង
៣៣- លោក កោះ សុខុម
៣៤- លោក គត់ ហ៊ីម
៣៥- លោក គីម អេង
៣៦- លោក រស់ សំប៊ុន
៣៧- លោក ផន ឃីម
៣៨- លោក ចត់ ស៊ីច័ន្ទ
៣៩- លោក ជៃ សៃ
៤០- លោក ព្រំ សុខឡូនា
៤១- លោក យូ សុផល
៤២- លោក ប៊ុន ជន
៤៣- លោក គីម ចិន្តា
៤៤- លោក ឈរ ចន្ថា
៤៥- លោក អ៊ុំ ចន្ធី
៤៦- លោក សរ សុផុន
៤៧- លោក ឡាំ ស្រ៊ីន
៤៨- លោក ម៉ៅ យ៉ាត
៤៩- លោក ពេញ ចន្ធី
៥០- លោក សួន ឃីន
៥១- លោក គង់ ហាច
៥២- លោក លឿង សាម៉េត
៥៣- លោក ឌឹម នល់
៥៤- លោក មុត ធិ
៥៥- លោក ភឿត ទី
៥៦- លោក សាំង ស៊ុយ
៥៧- លោក ស្វាយ បិន
៥៨- លោក ប្រាត់ ជុំ
៥៩- លោក ស៊ីម រ៉ាន
៦០- លោក ឃីម អេន
៦១- លោក យ៉ង់ អឿន
៦២- លោក គង់ ធុន
៦៣- លោក សុត ហួន
៦៤- លោក សិន ប៊ីត
៦៥- លោក ហ៊ុង ស៊ុន
៦៦- លោក គាំ ចណ្ណា
៦៧- លោក ឯល សេន
៦៨- លោក សួន សុផល
៦៩- លោក ម៉ម ឋិត
៧០- លោក អ៊ុម យុន
៧១- លោក មៀច ឡៃ
៧២- លោក ភុល យឿន
៧៣- លោក ជាយ យន
៧៤- លោក សួន អឿន
៧៥- លោក ជា ចំរើន
៧៦- លោក ញាន ឧន
៧៧- លោក អ៊ុម យ៉ាន
៧៨- លោក ម៉ែន ម៉ាន
៧៩- លោក ហៃ អុល
៨០- លោក គាំ សារុំ
៨១- លោក ឌុច ម៉ាត
៨២- លោក ម៉ៅ យ៉ុង
៨៣- លោក ឡុង អាន
៨៤- លោក ស្រស់ សេង
៨៥- លោក ម៉ៅ សារឿន
៨៦- លោក ឌឹម នឹម
៨៧- លោក ខឡូ នឿន
៨៨- លោក អ៊ុច យ៉ាន
៨៩- លោក អ៊ូ អ៊ុល
៩០- លោក ម៉ៅ បៀន

៩១- លោក ឃ្លោក ចន្ថា
៩២- លោក អែល សុខឡេង
៩៣- លោក ជួន សុខា
៩៤- លោក គឹម លន
៩៥- លោក ស ផាន់
៩៦- លោក ជួប ថាត
៩៧- លោក ម៉ែន សេត
៩៨- លោក មុំ ព្រួន
៩៩- លោក ឆេព ជា
១០០- លោក ស្រី ធូ
១០១- លោក ហេង ហាត់
១០២- លោក ហែម ប៊ីន
១០៣- លោក អ៊ុត ធី
១០៤- លោក គិន គា
១០៥- លោក ព្រុំ សុភី
១០៦- លោក គេង ហុត
១០៧- លោក ប្រាជ្ញ មូ
១០៨- លោក គល់ រ៉ាន់
១០៩- លោក ម៉ុត ជួប
១១០- លោក ព្រុំ សៀង
១១១- លោក ឃួច ទូត
១១២- លោក ប៊ិន ភាន
១១៣- លោក ហួង ហ៊ីម
១១៤- លោក វៃ ម៉ៅ
១១៥- លោក ជឹម ស៊ីម
១១៦- លោក ស៊ីង សែត
១១៧- លោក អ៊ុត សារី
១១៨- លោក សឿន សន
១១៩- លោក ប៊ុត ឈួង
១២០- លោក ប៊ុល ខាន
១២១- លោក លៀង លឹម
១២២- លោក ដួង សំ
១២៣- លោក អ៊ុន សន
១២៤- លោក សោម សុត
១២៥- លោក ណាង សុនាង
១២៦- លោក ចិន សាម៉ន

គ- មេដាយ សិរីទ្ធការងារ :

១- កញ្ញា ធឹម ពុទ្ធា
២- លោក សេស ស៊ីថា
៣- លោក ម៉ម សុផល
៤- លោក ប៉ត់ ឃៀង
៥- លោក ខឹម អុន
៦- លោក ម៉ត់ ផល្លី
៧- លោក យី ផល្លា
៨- លោក ប៊ូ ថាន្នី
៩- លោក មុយ ប៊ុនធឿន
១០- លោក ជា សារ៉ុន
១១- លោក អៀង ថុល
១២- លោក ជៀម វិចិត្រ
១៣- លោក ប៊ិន សន
១៤- លោក ស៊ិន ម៉ាន
១៥- លោក សៅ ថាត
១៦- លោក មុំ គេន
១៧- លោកស្រី ស្លា ខេន
១៨- លោក ជា សុខា
១៩- លោក លី សុវណ្ណ
២០- លោក ស៊ឹម ចន្ទី
២១- លោក អ៊ិន សាវៀត
២២- លោក តៃ រួន
២៣- លោក នួន សារុំ
២៤- លោក ផុន សាវ៉ាត
២៥- លោក តៃ ម៉ូត
២៦- លោក ប្រាក់ សុគុណ
២៧- លោក អ៊ុ សំអឿន
២៨- លោក ឈឹម ពៅ
២៩- លោក នង ផន
៣០- លោក តែង រិទ្ធី
៣១- លោក ឆេព សំអែល
៣២- លោក ឆេង សុខុន

៣៣- លោក ស៊ុំ សុខុម
៣៤- លោក ប៊ុន ភន
៣៥- លោក ចាន់ សុភ័ណ
៣៦- លោក ពុំ ហៀត
៣៧- លោក នូ សារ៉ាត់
៣៨- លោក ឃួន ខន
៣៩- លោក ប៉ម សារិន
៤០- លោក ធុច ស្រ៊ី
៤១- លោក លី លីមហួច
៤២- លោក ម្សៀច ម៉ៅ
៤៣- លោក តែង ហ៊ិន
៤៤- លោក ឃឹម ចិន
៤៥- លោក យ៉េត សារឿន
៤៦- លោក ឃុត ផេត
៤៧- លោក ហួន សារី
៤៨- លោក ម៉ិល ស្រ៊ុន
៤៩- លោក ពេជ ភារុន
៥០- លោក ឯក ឡូច
៥១- លោក កៅ ហ៊ីម
៥២- លោក ស៊ីង មឿន
៥៣- លោក ម៉ី ឡៃ
៥៤- លោក សៅ យាន
៥៥- លោក ហែន សុខ
៥៦- លោក ស៊ឹម អ៉ែន
៥៧- លោក សុខ ចាន់
៥៨- លោក ចិន គាន
៥៩- លោក ទុយ ឡៀច
៦០- លោក ជា ចណ្ណា
៦១- លោក សែម សារុំ
៦២- លោក បែន យី
៦៣- លោក នួន ទីន
៦៤- លោក យង់ សុន
៦៥- លោក គុន កៅ
៦៦- លោក ពេញ ដៃ
៦៧- លោក ខាត់ យ៉ុន
៦៨- លោក ឈិន សាជិ
៦៩- លោក សន សៀន
៧០- លោក សុត ស៊ុយ
៧១- លោក ផៃ ប៊ុនថុល
៧២- លោក សុខ សោន
៧៣- លោក ឡាយ ចាន់នី
៧៤- លោក យ៉េម រុន
៧៥- លោក ហាឡ្យ ឈិន
៧៦- លោក ហែម សៀន
៧៧- លោក មូល គ្រី
៧៨- លោក គីង នី
៧៩- លោក ឃ្លាត សៀត
៨០- លោក មឿច ហេច
៨១- លោក សួស សាន់
៨២- លោក គឹម ថាន
៨៣- លោក ធាំ ហ៊ីម
៨៤- លោក ឆាង ប៉ាត
៨៥- លោក អ៊ុច យៀន
៨៦- លោក សួត យ៉េន
៨៧- លោក ចាន់ ម៉ាត់
៨៨- លោក ប៊ុន អាន
៨៩- លោក ចត់ ថៃ
៩០- លោក គង់ សារិន
៩១- លោក តុយ តឿន
៩២- លោក ពៅ សារ៉ាត់
៩៣- លោក នច ច៉េន
៩៤- លោក ព្រំ ស៊ីណាត
៩៥- លោក សេត ទិន
៩៦- លោក តឿត ហ៊ុន
៩៧- លោក សុខ មឿន
៩៨- លោក សែម ចាន់ធាន
៩៩- លោក ដួន យ៉េន
១០០- លោក ឃួន សំបួរ
១០១- លោក ឃឹម ច៉ៅ
១០២- លោក អ៊ឹត ដា
១០៣- លោក ឈន សុខុម
១០៤- លោក ប្រាក់ ឡុន

១០៥- លោក រសេខ គួយ
១០៦- លោក ឡូខ ចំរើន
១០៧- លោក រូន សុខលីម
១០៨- លោក ខ្លឹម ម៉ូ
១០៩- លោក នុត សុថុន
១១០- លោក វ៉ៀវ សុនៅ
១១១- លោក សេត អ៊ុន
១១២- លោក ឧន់ យ៉ុត
១១៣- លោក កែវ ឈុន
១១៤- លោក ចាប ឈឹន
១១៥- លោក សៀវ ថូ
១១៦- លោក យុត ចាន់ធឿន
១១៧- លោក ស៊ឹម ថេន
១១៨- លោក ជា សៀវ
១១៩- លោក រាជ សាមុត
១២០- លោក ជា នឹម
១២១- លោក អ៊ុត បួរ
១២២- លោក បៀន ម៉ន
១២៣- លោក ថាប់ សារ៉ែត

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/០២/ រកត /០៩០៨/ ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស រកម/ ០១៩៦ /០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ ៨៤/ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១:** តែងតាំងលោក **ព្រំ ប៊ុណ្ណយី** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកីឡា នៃក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា២:** តែងតាំងលោក **ដួង មាសចំរើន** ជាប្រធាននាយកដ្ឋានអប់រំកាយ និងកីឡា សិស្ស និស្សិត ជំនួសលោក ព្រំ ប៊ុណ្ណយី ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១-មាត្រា២ ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..៧៤..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដំឡើងឋានន្តរសក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរសក្តិមន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន **០២** រូប ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១ | **ឡាយ ឬទ្ធី** | ប | ពី អនុមន្ត្រី ថ្នាក់លេខ ៦ | ទៅ វរមន្ត្រី ថ្នាក់លេខ ៧ |
| ២ | **គុណា ញឹម** | ប | ពី អនុមន្ត្រី ថ្នាក់លេខ ៧ | ទៅ វរមន្ត្រី ថ្នាក់លេខ ៨ |

**មាត្រា ២ :** ត្រូវបានដំឡើងឋានន្តរសក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន **០៣** រូប ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១ | **ហ៊ឹម ថុរ៉ា** | ប | ពី មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨ | ទៅ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២ | **ឈឹម ផល្លា** | ប | ពី មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១០ | ទៅ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ |
| ៣ | **គីម គិរុណា** | ប | ពី មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១១ | ទៅ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ |

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ [illegible] ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៤៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ចំនួន០១គ្រឿង ជូនលោក Thierry BANGRATZ ទីប្រឹក្សាទូទៅ (General Advisor) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំធនាគារជាតិនៃកម្ពុជា ដែលបានសហការល្អជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការរៀបចំឯកសារ គោលនយោបាយ និងវិធីសាស្ត្រក្នុងការពង្រឹងប្រព័ន្ធធនាគារនៅកម្ពុជា រួមចំណែកបម្រើវិស័យសេដ្ឋកិច្ច រយៈពេល០៣ឆ្នាំកន្លងមក ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ចំនួន០១គ្រឿង ជូនលោក **ឌូក្លាស អេ.ចេ ឡាតហ្វត** ( Mr.Douglas A.J Latchford) ដែលកន្លងមកក៏ដូចបច្ចុប្បន្ន តែងបានសហការល្អជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងបានផ្តល់នូវវត្ថុបុរាណ ចម្លាក់លំអក្បាលទូករូបគ្រុឌ មានកំពស់ ៩៣ ស.ម សម្រាប់តំកល់ទុកនៅក្នុងសារមន្ទីរជាតិភ្នំពេញ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូន Ms. Maria Gen Dungo ដែលបានផ្តល់នូវប្រព័ន្ធទិន្នន័យ (Database) និងបណ្តាញ (Network) ដល់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីជាគុណប្រយោជន៍ដល់ដំណើរការគ្រប់គ្រងមន្ត្រី បុគ្គលិក និងនិស្សិត ចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤៥ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន០៨រូប ដែលបានផ្ដល់នូវប្រព័ន្ធទិន្នន័យ (Database) និងបណ្ដាញ (Network) ដល់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីជាគុណប្រយោជន៍ដល់ដំណើរការគ្រប់គ្រងមន្ត្រី បុគ្គលិក និងនិស្សិត ចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | ម៉ៃ | ប៊ុនថា |
| ២-លោក | ស្រង់ | ផល្លី |
| ៣-លោក | ឆេព | តែន |
| ៤-លោក | ឆេព | តុល |
| ៥-លោក | ឆេព | សុវ៉ាន់ដារ៉ា |
| ៦-លោក | អ៊ា | ប្រុស |
| ៧-លោក | ជា | លីទុធ |
| ៨-លោក | ថុក | ណារិទ្ធ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០១១

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៤៧ អនក្រ.ធក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ដំបូលព្រះវិហារ សាលាបាលី មហាកុដិធម្មត្រៃយ៍ និងរបងវត្ត នៅ**វត្តបុទុមគង្គារ** ហៅ (វត្តព្រែកដាច់) ស្ថិតនៅក្នុងឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ម៉ាន់ ហឿង** | គង់នៅវត្តបុទុមគង្គារ | បច្ច័យចំនួន ១០.១៤៩ ដុល្លារ |
| ២-ព្រះតេជគុណខន្តិកោ | **ហ៊ុយ អ៊ុល** | ព្រះចៅអធិការវត្តបុទុមគង្គារ | បច្ច័យចំនួន ១០.០៥២ ដុល្លារ |
| ៣-លោក | **ម៉ាន់ លាន** | អាចារ្យវត្តបុទុមគង្គារ | ថវិកាចំនួន ១១.០៥០ ដុល្លារ |
| ៤-លោកជំទាវ | **វង្ស សារី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៦០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០២ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **គួច ឡុច** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៨.២១០ ដុល្លារ |
| ២-លោក | **យ៉ិន សំរឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៧.៧០៥ ដុល្លារ |

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកណ្តាល និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនគ្រឿងឥស្សរិយយសសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧04/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ 0២/នស/៩៤ ចុះថ្ងៃទី ២0 ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១0៩៥/0១ ចុះថ្ងៃទី 0៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសសមុនីសារាភ័ណ្ឌ**ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណរតនៈសីលោ **ឈឿន ម៉ុនលី** គ្រូសូត្រស្ដាំវត្តបុទុមគង្គារ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ដំបូលព្រះវិហារ សាលាបាលី មហាកុដិធម្មត្រៃយ៍ និងរបងវត្ត នៅ**វត្តបុទុមគង្គារ** ហៅ (វត្តព្រែកដាច់) ស្ថិតនៅក្នុងឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្ដាល **ចំណាយអស់ថវិកាសរុបចំនួន៧១.២៣៤ ដុល្លារ** ។

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកណ្ដាល និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
